+855 (0)17774864
www.sasabassac.com

#18 2nd Floor, Sothearos Boulevard
PO Box 2181 Phnom Penh 3, Cambodia

ស-សបាសាក់ SA SA BASSAC

# កញ្ចប់អនាគត

## ដោយ  លីម សុខចាន់លីណា

របង របាំងហ៊ុមព័ទ្ធបណ្ដោះអាសន្ន បន្ទាត់ខណ្ឌ។ សញ្ញាបញ្ជាក់ពីការផ្លាស់ប្ដូរទាំងអស់នេះ កាន់តែឃើញមានច្រើនឡើងៗ ហើយក្លាយជាទិដ្ឋភាពដ៏សាមញ្ញមួយនៃរាជធានីភ្នំពេញសព្វថ្ងៃ។ តាំងតែពីចាប់ផ្ដើមមានការសាងសង់សំណង់ខ្ពស់ៗនៅក្នុងក្រុងនាឆ្នាំ ២០០៩ មក  លីម សុខចាន់លីណា បានចាប់អារម្មណ៍ពីព្រំដែននៃគម្រោងអភិវឌ្ឍជាតិដែលសន្យាថានឹងនាំមកនូវរូបភាព «ភ្នំពេញថ្មី» មួយដែលមានភាពប្រសើរជាងមុន។ ដោយបានទៅពិនិត្យជាច្រើនលើកច្រើនសារ ជាពិសេសនៅតំបន់ដែលមានរឿងចម្រូងចម្រាស សិល្បករចង់បំផុសនូវសំណួរអំពីព្រំដែនពិតនិងព្រំដែនតំណាងនៃរបាំងទាំងនេះ ក្នុងការខណ្ឌចែករវាងភាពជាសាធារណៈនិងភាពជាឯកជន អតីតកាលនិងអនាគតកាល ការស្គាល់និងការមិនស្គាល់។

សិល្បករនិយាយថា៖ «ដីដែលព័ទ្ធរបងលែងមានន័យទៀតហើយ។ អ្វីដែលត្រូវបំផ្លាញចោលរើរចេញពីទីតាំងទាំងនេះហាក់ដូចជាលែងមានសារៈសំខាន់ទៀតហើយ។ ការចងចាំត្រូវបានជួញដូរដោយការអភិវឌ្ឍន៍។ តើគេនឹងសង់អ្វីទៅ បើគេជឿជាក់យ៉ាងខ្លាំងថាអនាគតគឺជាក្ដីបារម្ភតែមួយមុខប៉ុណ្ណោះ។ របងទាំងនេះវេចខ្ចប់នូវអនាគត ដែលមកជំនួសនូវអ្វីដែលគេបំភ្លេចចោល ឬមិនដែលទាំងស្គាល់។»

លីណា ថតពីរបាំងបណ្ដោះអាសន្នទាំងអស់នេះ ក្នុងលក្ខណៈជាឯកសារផង និងជាសិល្បៈផង។ គាត់បានប្រិតប្រៀងរៀបប្លង់ថតនៅក្រោមពន្លឺថ្ងៃត្រង់ ហើយពណ៌នៅក្នុងរូបធ្វើអោយរបងបង្ហាំងដ៏សម្បើមទាំងនោះមើលទៅរាបស្មើនិងធម្មតា។ ពណ៌ ក្បាច់ ស្នាមពៀច ច្រេះ ធូលី និង គំនូសស្នាម នាំឱ្យគេពិនិត្យមើលរូបថតទាំងនេះដូចជាការគយគន់ផ្ទាំងគំនូរដូច្នោះដែរ។  ចំណងជើងនៃរូបភាព នីមួយៗ គឺកត់ត្រាពីអ្វីដែលបានកើតឡើង នៅទីណា និងនៅពេលណា។ អាគារចាស់សម័យអាណានិគម បារាំង ត្រូវបានចងចាំទុកនៅក្នុងរូបថតដែលមានចំណងជើងថា អតីតក្រសួងទេសចរណ៍ *មហាវិថីព្រះ សុធារស និងតិរវិថីព្រះស៊ីសុវត្ថិ ២០០៩*។ រីឯស្នាដៃរបស់លោក វណ្ណ ម៉ូលីវណ្ណ ដែលជាស្ថាបត្យករដ៏ល្បីល្បាញរបស់កម្ពុជា បណ្ដុះបណ្ដាលដោយលោកក័រប៊ុស្សៀ  ត្រូវបានរំលឹកឡើងនៅក្នុងរូបថត *អតីតសាលមហោស្រព្យជាតិព្រះសុរាម្រឹត ផ្លូវសភាជាតិ ២០០៩*។ ចំណែកសហគមន៍ដែលត្រូវបានជម្លៀសចេញពីទីក្រុង ត្រូវបានផ្ដល់កិត្តិយសនៅក្នុងរូបថត  *អតីតបុរីកីឡា ជញ្ជាំងខាងត្បូង មហាវិថីឆេកូស្លូវ៉ាគី ចន្លោះផ្លូវ១៥២និង១៦៤  ២០១២*។

ពិព័រណ៍ទោល *កញ្ចប់អនាគត* របស់លីណា ដោយផ្អែកលើស្នាដៃរូបថតដែលមានចំណងជើងដូចគ្នា គឺជាការងារបែប Installation យ៉ាងសាមញ្ញប៉ុន្តែប្រកបដោយឥទ្ធិពល ស្ដីពីព្រំដែនពិតនិងតំណាង។ របងស័ង្កសីបានបាំងមួយផ្នែកធំនៃវិចិត្រសាល តំណាងអោយទិដ្ឋភាពទីក្រុង។ នៅក្នុងបន្ទប់តូច មានរូបថតនៃរបងមួយ និងសៀវភៅនៃកំរងរូបថត ដែលអាចអោយអ្នកទស្សនាបើកមើលបាន។ នៅទីនេះ ដោយបានឃ្លាតឆ្ងាយពីមជ្ឈដ្ឋានកុះករនៅជុំវិញ និងវាសនាមិនទៀងទាត់របស់វា របងនេះបែជាក្លាយជាតំបន់អចិន្ត្រៃយ៍និងបានកត់ត្រាទុក។ ហេតុដូចនេះ អ្វីដែលរបងទាំងនេះហ៊ុមព័ទ្ធលាក់កំបាំង និងអ្វីដែលវានឹងបង្ហាញនៅចុងក្រោយអាចចោទជាសំណួរបាន។

**អំពីសិល្បករ**៖ លីម សុខចាន់លីណា (កើតនៅព្រៃវែង ឆ្នាំ១៩៨៧) ធ្វើការងារបែបដកស្រង់ឯកសារ និងបែបជាគំនិត ដោយប្រើប្រាស់រូបថត Installation និងការសម្ដែង។ គាត់ប្រើយុទ្ធសាស្ត្រផ្សេងៗគ្នាដោយទាញចំណាប់អារម្មណ៍ដល់ការផ្លាស់ប្ដូរជាច្រើនរបស់សង្គម វប្បធម៌ សេដ្ឋកិច្ច និងបរិស្ថាននៅកម្ពុជាដែលកើតចេញពីសកលភាវូបនីយកម្ម។ គាត់ជាស្ថាបនិកនិងសមាជិកសកម្មម្នាក់នៅក្នុងក្រុមស្ទាវសិល្បៈ និងគម្រោងសិល្បៈ ស-ស។ លីណា បានតាំងពិព័រណ៍នៅពាសពេញប្រទេសកម្ពុជា រួមទាំងនៅសារមន្ទីរជាតិផងដែរ។ ពិព័រណ៍ ទោលរបស់គាត់រួមមាន *ម៉ូតូខ្ញុំនិងរូបខ្ញុំ* (មហោស្រពរូបថតភ្នំពេញ ២០០៩) និង *កញ្ចប់អនាគត* (ស-ស បាសាក់ ភ្នំពេញ ២០១២)។ ពិព័រណ៍ជាក្រុមនៅឆ្នាំ ២០១២ រួមមាន *ការកាត់ផ្ដាច់និងរស់ឡើងវិញៈ វិស័យថតរូប របស់កម្ពុជាក្នុងទសវត្សមុន* វិទ្យាស្ថានសិល្បៈ សហសម័យសិង្ហបុរី, *រវាងការស្រមើស្រមៃ និងការពិត* មហោស្រពរូបថតទាក់ទង វិចិត្រសាលខាងកើត នៅទីក្រុងតូរ៉ុនតូ, *ទិដ្ឋភាពទន្លេក្នុងការផ្លាស់ប្ដូរ* ពិព័រណ៍ថ្នាក់តំបន់ ហាណូយ ហូជីមិញ ម៉ានីល ភ្នំពេញ បាងកក និង ចាការតា។

# Wrapped Future

## Lim Sokchanlina

Fences. Makeshift enclosures. Dividing lines. These increasingly present indicators of change define much of Phnom Penh's topography today. Since the onset of heightened urban construction in 2009, Lim Sokchanlina became interested in the border-making practices of national development schemes that promise a better "New Phnom Penh". Repeat visits to especially contentious sites provoked his questioning not only the physical borders but also their psychological ability to divide public and private, past and future, known and unknown.

Says the artist, "The land enclosed is no longer a presence, as if what was destroyed at these sites no longer matter. Memory has been traded for development. What will be erected with a strict belief that the future is the only concern? These fences are wrapping the future, standing in place of what was forgotten or never even known."

With both archival and artistic impulse, Lim photographs these temporary partitions. Carefully composed under the brightness of midday sunlight, his corrugated color fields flatten the imposing fences into mundane facades. Colors, patterns, dents, rust, dirt, and markings invite a painterly inspection, while titles serve to keep a record of what was where when. The ghost of a landmark colonial building is remembered in *Former Ministry of Tourism, Sothearos Boulvard and Sisowath Quay, 2009*. Cambodia's iconic Corbusier-trained architect Vann Molyvann's work is mourned in *Former Preah Suramarit National Theatre, National Assembly Street, 2009*. Communities of displaced people are honored in *Former Borei Keila, South Wall, Czechoslavakia Boulevard, between Street 152 and Street 164, 2012*.

Lim's solo exhibition *Wrapped Future*, based on his photographic series under the same name, is a bold and minimalist installation of real and representational borders. A commanding corrugated metal fence blocks access to the majority of the large gallery space, enforcing the urban panorama. In the smaller space one relatively quiet photograph of a fence hangs and a new book of the photographic series can also be paged through. Here, isolated to the image, away from their bustling surroundings and ephemeral fate, the fences become permanent, recorded landmarks. As such, what they conceal, and ultimately what they will reveal, can be called into question.

**About the Artist**

Lim Sokchanlina (born Prey Veng, 1987) works across documentary and conceptual practices with photography, installation and performance. Using different strategies, he calls attention to a variety of social, cultural, economic and environmental changes in Cambodia resulting from globalization. He is a founding and active member of the artist collective Stiev Selepak / Art Rebels. Lim has exhibited widely in Cambodia, including at the National Museum. His solo shows include *My Motorbike and Me* (PhotoPhnomPenh, 2009) and *Wrapped Future* (SA SA BASSAC, Phnom Penh, 2012). Group exhibitions in 2012 include *Rupture and Revival: Cambodian Photography in the Last Decade*, Institute of Contemporary Arts Singapore; *Between Fantasy and Reality*, Contact Photo Festival, The East Gallery, Toronto; *Riverscapes IN FLUX*, a regional exhibition in Hanoi, Ho Chi Minh City, Manilla, Phnom Penh, Bangkok, and Jakarta.

# កញ្ចប់អនាគត
## ដោយ  លីម សុខចាន់លីណា

# Wrapped Future
## Lim Sokchanlina

3 March – 1 April 2012



*Former Dey Krohom, East Wall, between Sothearos Boulevard and National Assembly Street, 2009*



*Wrapped Future*, installation view, SA SA BASSAC, 2012